**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន អនុញ្ញាតឲ្យ ឯកឧត្តម** Philippe Kridelka
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្របែលហ្ស៊ិកប្រចាំកម្ពុជា**
**ដែលមាននិវេសដ្ឋាននៅបាងកក ជួបសម្តែងការគួរសម និងជម្រាបលា តាមទូរស័ព្ទ**

នាព្រឹកថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ ឯកឧត្តម Philippe Kridelka ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្របែលហ្ស៊ិកប្រចាំកម្ពុជា ដែលមាននិវេសដ្ឋាននៅបាងកក ជួបសម្តែងការគួរសម និងជម្រាបលា តាមទូរស័ព្ទ បន្ទាប់ពីបានបញ្ចប់បេសកកម្មការទូតរបស់ខ្លួន។

ឯកឧត្តមឯកអគ្គរាជទូត បានថ្លែងអំណរគុណចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ផ្ទាល់ ក៏ដូចជាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដែលបានផ្តល់ការគាំទ្រដល់បេសកកម្មការទូតរបស់ឯកឧត្តម នាពេលកន្លងមក។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះបែលហ្ស៊ិក ដែលបានរួមចំណែកក្នុងការអភិវឌ្ឍនៅកម្ពុជា នាពេលកន្លងមក ក្នុងវិស័យមួយចំនួនដូចជា អប់រំ សុខាភិបាល និងការបោសសំអាតមីន ក៏ដូចជាការរួមចំណែកក្នុងដំណើរការសាលាក្តីខ្មែរក្រហមផងដែរ។ ទន្ទឹមនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអរគុណផងដែរចំពោះបែលហ្ស៊ិក ដែលចាត់ទុកកម្ពុជាជាប្រទេសមួយ ក្នុងចំណោមប្រទេសអាទិភាពទាំង ៣០ សម្រាប់ទទួលជំនួយអភិវឌ្ឍន៍។

ពាក់ព័ន្ធនឹងការងារកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ឯកឧត្តមឯកអគ្គរាជទូតបានលើកឡើងថា បែលហ្ស៊ិកមានបំណងជួយអភិវឌ្ឍន៍តំបន់ប្រសាទព្រះវិហារ និងបានចាត់ទុកប្រាសាទព្រះវិហារជាសម្បត្តិទេសចរណ៍វប្បធម៌មានសារៈសំខាន់សម្រាប់កម្ពុជា និងមានសក្តានុពលក្នុងការទាក់ទាញភ្ញៀវទេសចរមិនចាញ់ប្រាសាទអង្គរវត្តឡើយ។

ដោយកម្ពុជា និងបែលហ្ស៊ិក ទើបបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជំរុញឲ្យមានការរៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី១ នៅភ្នំពេញ ឬព្រុចសែល បន្ទាប់ពីវិបត្តិកូវីដ-១៩ មានការថមថយទៅវិញ ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការផ្សេងៗ រួមទាំងគម្រោងខាងលើផងដែរ។

ភាគីបែលហ្ស៊ិក ក៏បានស្នើកម្ពុជាពិចារណាឲ្យមានការចរចាកិច្ចព្រមព្រៀងស្តីពីការផ្លាស់ប្តូរទណ្ឌិត រវាងកម្ពុជា និងបែកហ្ស៊ិកផងដែរ។

ឯកឧត្តមឯកអគ្គរាជទូត បានជម្រាបជូនអំពីចំណាប់អារម្មណ៍របស់សហភាពអឺរ៉ុប ចំពោះកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈកម្មការទន្លេមេគង្គ។ ជាការឆ្លើយតប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍតំបន់ទន្លេមេគង្គ ដែលជាទន្លេធំមួយ

ក្នុងចំណោមទន្លេធំៗលើពិភពលោក។ បច្ចុប្បន្ននេះ មានយន្តការសហប្រតិបត្តិការជាច្រើនជាមួយបណ្តាប្រទេសមួយចំនួនដូចជា ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ  សហរដ្ឋអាមេរិក និងឥណ្ឌា។

ក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ភាគីទាំងពីរក៏បានពិភាក្សាគ្នាផងដែរ អំពីការចូលរួមរបស់កម្ពុជាក្នុងការថែរក្សាសន្តិភាពនៅក្នុងបណ្តាប្រទេសដូចជា លីបង់ ម៉ាលី អាហ្វ្រិកកណ្តាល ស៊ូដង់ និងស៊ូដង់ខាងត្បូង។ ទន្ទឹមនឹងនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ផងដែរអំពីសារៈសំខាន់នៃពហុភាគីនិយម។

ជាទីបញ្ចប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានអបអរសាទរ និងជូនពរឯកឧត្តមឯកអគ្គរាជទូតឲ្យទទួលបានជោគជ័យក្នុងភារកិច្ចថ្មី និងត្រៀមផ្តល់កិច្ចសហការល្អដល់ឯកអគ្គរាជទូតថ្មី ដែលនឹងចូលកាន់តំណែងក្នុងពេលឆាប់ៗខាងមុខនេះ៕

---------------